**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១១០០៥ សហវ.អហថ

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២៣

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ÷** ស្នើសុំកិច្ចសម្របសម្រួលប្រមូលធាតុចូលពីរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ សម្រាប់ជាមូលដ្ឋានរៀបចំ “សេចក្តីណែនាំស្តីពីការគ្រប់គ្រងនិងការប្រើថវិកាសេវាសង្គម និងអនាម័យបរិស្ថានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់”។

**ភ្ជាប់ជូន÷** សេចក្តីព្រាងឧបសម្ព័ន្ធ នៃសេចក្តីណែនាំស្តីពីការគ្រប់គ្រងនិងការប្រើថវិកាសេវាសង្គម និងអនាម័យបរិស្ថានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្តជ្រាបថា÷ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិជាសេនាធិការ កំពុងរៀបចំសេចក្តីណែនាំស្តីពីការគ្រប់គ្រងនិងការប្រើថវិកាសេវាសង្គម និងអនាម័យបរិស្ថានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីដាក់ឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ទូទាំងប្រទេសអនុវត្តចាប់ពីឆ្នាំ២០២៤ តទៅ។ ដោយឡែកសម្រាប់ការប្រើថវិកាអនាម័យបរិស្ថានរបស់រដ្ឋបាលឃុំ សង្កាត់ នឹងចាប់ផ្តើមអនុវត្តពីឆ្នាំ២០២៥។ ដើម្បីឱ្យសេចក្តីណែនាំខាងលើអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើសុំកិច្ចសម្របសម្រួលពីឯកឧត្តម លោកជំទាវ ជាអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីប្រមូលធាតុចូលពីរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់សាមី នូវព័ត៌មានដូចខាងក្រោម÷

- រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ធ្វើការជ្រើសរើសសកម្មភាពអាទិភាពដែលរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់សាមី ធ្លាប់បានអនុវត្ត និង/ឬសកម្មភាព ដែលគ្រោងនឹងអនុវត្តពីក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជូន ដោយបញ្ជាក់ពីលេខអនុគណនីនៃមាតិកាថវិកា និងទំហំថវិកាជាក់ស្តែងសម្រាប់គ្រោងប្រើក្នុងឆ្នាំ ២០២៤ (សូមបរិយាយ ពីសកម្មភាព/គម្រោងសេវាសង្គមនិងអនាម័យបរិស្ថានបន្ថែម)។
- រដ្ឋបាលក្រុង ស្រុក អាចបន្ថែមសកម្មភាពផ្សេងទៀតដែលរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់សាមី យល់ថាចាំបាច់ និងមិនមានក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជូន ដោយបញ្ជាក់ពីលេខអនុគណនីនៃមាតិកាថវិកា និងទំហំថវិកា (សូមបរិយាយពីសកម្មភាព/គម្រោងសេវាសង្គមនិងអនាម័យបរិស្ថានបន្ថែម)។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្តពិនិត្យនិងចាត់ចែងប្រមូលធាតុចូល និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរ ត្រឹមថ្ងៃទី ខែ ឆ្នាំ២០២៣ កុំបីខាន។

សូមឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានពីខ្ញុំ

**រដ្ឋលេខាធិការ**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត.ជូ-គីមឡេង**

<u>ព័ត៌មានបន្ថែមសូមទាក់ទង</u>

-លោក ថន សីលា ទូរស័ព្ទ÷ ០៩២ ២៦ ២៦ ៥៧

-លោក ចាន់ ហេងលី ទូរស័ព្ទ÷ ០១២ ៧៦ ៥៥ ០៤

**ចម្លងជូន÷**

*-រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់*

*(ដើម្បីអនុវត្ត)*

# ឧបសម្ព័ន្ធ

## សកម្មភាពសេវាសង្គមនិងបរិស្ថាន និង មាតិកាថវិកា

| បរិយាយសេវាសង្គមនិងបរិស្ថាន | មាតិកាថវិកា | ជ្រើសរើស |
|---|---|---|
| **១.សេវាសង្គម** | | |
| **១.១. សុខភាពមាតា កុមារ និងអាហារូបត្ថម្ភ** | | |
| - ចំណាយសម្រាប់ការធ្វើដំណើរក្នុងការចុះត្រួតពិនិត្យស្ត្រីមានផ្ទៃពោះ និងកុមារក្រោម៥ឆ្នាំ ដើម្បីកំណត់រកអ្នកមានបញ្ហាអាហារូបត្ថម្ភ។<br>- ចំណាយសម្រាប់ការធ្វើដំណើរ ដើម្បីចុះផ្សព្វផ្សាយបង្កើនការយល់ដឹង និងការព្យាបាលដល់ម្តាយ និងកុមារដែលមានបញ្ហាអាហារូបត្ថម្ភ នៅសហគមន៍។ | - 60015 “ប្រេងឥន្ធនៈ និងប្រេងរំអិល”<br>- 61021 “ការជួលមធ្យោបាយដឹកជញ្ជូន”<br>- 61121 “សោហ៊ុយដឹកជញ្ជូន”<br>- 61122 “សោហ៊ុយបេសកកម្ម”<br>- 61123 “សោហ៊ុយស្នាក់នៅ” | ☐<br>☐<br>☐<br>☐<br>☐ |
| - ចំណាយសម្រាប់រៀបចំបណ្តុះបណ្តាល កិច្ចប្រជុំ បង្កើនការយល់ដឹងតាមសហគមន៍ (តាមភូមិ ឬមណ្ឌលសុខភាព ឬនៅសាលាឃុំ សង្កាត់ ឬនៅតាមសាលារៀន) អំពីបញ្ហាសុខភាព និងអាហារូបត្ថម្ភរបស់មាតា និងកុមារ។ | - 61041 “សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស”<br>- 61103 “ប្រជុំ សិក្ខាសាលា និងសន្និសីទ” | ☐<br>☐ |
| - ចំណាយសម្រាប់ដឹកជញ្ជូនអ្នកជំងឺ (ស្ត្រីមានផ្ទៃពោះ និងកុមារដែលមានបញ្ហាអាហារូបត្ថម្ភ និងកុមារពិការ ) មកពីគ្រួសារក្រីក្រ ដើម្បីរកទទួលបានការព្យាបាល នៅមណ្ឌលសុខភាព និង/ឬមន្ទីរពេទ្យ។<br>- ចំណាយសម្រាប់ដឹកជញ្ជូនស្ត្រីមានផ្ទៃពោះ និងទារកទើបនឹងកើត (មកពីគ្រួសារក្រីក្រ) ទៅមណ្ឌលសុខភាព និង/ឬមន្ទីរពេទ្យ ដើម្បីពិនិត្យផ្ទៃពោះ និងទទួលបានការថែទាំក្រោយសម្រាល។ | - 61021 “ការជួលមធ្យោបាយដឹកជញ្ជូន” | ☐ |
| - សាងសង់មណ្ឌលសុខភាពថ្មី ឬជួសជុលមណ្ឌលសុខភាពមានស្រាប់។<br>- ជួសជុលបន្ទប់រង់ចាំមុន និងក្រោយសម្រាល អគារ និងរបងមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក។ | - 21031 “សំណង់អគារ”<br>- 21032 “កែលម្អអគារ”<br>- 61052 “ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ”<br>- 60012“សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ” | ☐<br>☐<br>☐<br>☐ |

| ១.២.ទឹកស្អាត និងអនាម័យ | | |
|---|---|---|
| - ចំណាយសម្រាប់ជួសជុល សាងសង់កន្លែងលាងដៃ បង្គន់ នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។<br>- ចំណាយសម្រាប់សេវាថែទាំ និងជួសជុលឧបករណ៍ និងការបំពាក់សម្ភារៈទឹកស្អាត និងអនាម័យនៅតាមមណ្ឌលសុខភាពមត្តេយ្យសិក្សាសហគមន៍ សាលាឃុំ និងសាលារៀន (ការបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ និងស្ត្រី រួមមានការកែសម្រួលជម្រាលបង្កាន់ដៃ ជណ្តើរ និងដៃស្ទប់អណ្តូង និងកន្លែងទុកដាក់ក្រដាសអនាម័យ ប្រដាប់លាងសម្អាតដៃ និងសាប៊ូ)។ | - 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ"<br>- 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទ និងសំណង់ផ្សេងៗ"<br>- 61057 "ការថែទាំ និងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស"<br>- 60018 "សម្ភារៈផ្គត់ផ្គង់ថែទាំផ្សេងៗ" | ☐<br>☐<br>☐<br>☐ |
| - ចំណាយសាងសង់ ជួសជុលអណ្តូងទឹក ការតភ្ជាប់បណ្តាញផ្គត់ផ្គង់ទឹក នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។<br>- សម្ភារៈភ្ជាប់បណ្តាញទឹក និងសម្ភារៈសម្រាប់សាងសង់បង្គន់អនាម័យដូចជា ចានបង្គន់ កង់លូ។<br>- ចំណាយសម្រាប់តបណ្តាញទឹកស្អាត និងបំពាក់សម្ភារៈអនាម័យនៅតាមមណ្ឌលសុខភាព មត្តេយ្យសិក្សាសហគមន៍ សាលារៀន និងសាលាឃុំ សង្កាត់។ | - 61054 "ការថែទាំបណ្តាញផ្សេងៗ"<br>- 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទ និងសំណង់ផ្សេងៗ"<br>- 60053 "សម្ភារៈប្រើប្រាស់ "ដូចជាធុងទឹក ពាងទឹក ធុងចម្រោះ សម្ភារៈអនាម័យសម្រាប់កូនក្មេង | ☐<br>☐<br>☐ |
| - បំពាក់ម៉ាស៊ីន ឬប្រព័ន្ធចម្រោះទឹកស្អាត នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។ | - 60051 "សម្ភារៈនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា" | ☐ |
| - ផ្តល់សាប៊ូនិងសម្ភារៈសម្អាតអនាម័យ នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។<br>- ចំណាយលើការទិញសម្ភារៈផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដល់សាលាឃុំ សង្កាត់ មណ្ឌលសុខភាព មត្តេយ្យសិក្សាសហគមន៍ សាលារៀន (សម្ភារៈសម្អាតដៃ សាប៊ូ)។ | - 60011 "សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ" | ☐ |
| - ការផ្តល់ធុងទឹកនៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។<br>- ធុងទឹក ពាងទឹក ធុងចម្រោះសម្ភារៈអនាម័យសម្រាប់កូនក្មេង។ | - 60053 "សម្ភារៈប្រើប្រាស់" | ☐ |

| | | |
|---|---|---|
| - ទិញបង្គន់ចល័ត សម្រាប់ប្រើប្រាស់នៅតាមសាលារៀន (រួមទាំងមត្តេយ្យសិក្សា) នៅតាមមូលដ្ឋានសុខាភិបាល និងតាមទីសាធារណៈ។ | - 60058 "ការទិញសម្ភារៈតូចតាចសង្ហារិម និងសម្ភារៈបរិក្ខាផ្សេងៗ" | ☐ |
| - ចំណាយសម្រាប់ការធ្វើដំណើរ ដើម្បីរៀបចំកិច្ចប្រជុំ បង្កើនការយល់ដឹង រៀបចំនិងអនុវត្តផែនការ លើកកម្ពស់ទឹកស្អាត និងអនាម័យតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។<br>- ចំណាយធ្វើដំណើរ សម្រាប់ចុះពិនិត្យតាមដាន។<br>- ចំណាយសម្រាប់ការធ្វើដំណើរ រៀបចំកិច្ចប្រជុំបំផុស និងអនុវត្តផែនការសម្រាប់សហគមន៍ ដឹកនាំអនាម័យទាំងស្រុងនៅតាមសហគមន៍នានា។ | - 60015 "ប្រេងឥន្ធនៈនិងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" | ☐<br>☐<br>☐<br>☐<br>☐ |
| - ចំណាយសម្រាប់រៀបចំកិច្ចប្រជុំអំពីការគ្រោងផែនការ និងអនុវត្តផែនការសម្រាប់សហគមន៍ ដឹកនាំអនាម័យទាំងស្រុង តាមសហគមន៍។<br>- រៀបចំកិច្ចប្រជុំ បង្កើនការយល់ដឹងលើការរៀបចំ និងអនុវត្តផែនការលើកកម្ពស់ទឹកស្អាត និងអនាម័យតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល។ | - 61041 "សោហ៊ុយបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" | ☐<br>☐ |
| - ចំណាយឧបត្ថម្ភដល់សហគមន៍ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងការផ្ដល់សេវាអនាម័យដូចជា÷ ការសាងសង់ និងជួសជុលអណ្ដូងទឹក/បង្គន់ និងការតភ្ជាប់បណ្ដាញផ្គត់ផ្គង់ទឹក ការទិញបង្គន់ចល័តនៅតាមសហគមន៍ជាដើម។ | - 62031 "ឧបត្ថម្ភសហគមន៍ និងរក្សាសណ្ដាប់ធ្នាប់ សន្តិសុខសង្គម" | ☐ |
| **១.៣.ការអប់រំកុមារតូច** | | |
| - ចំណាយសម្រាប់សាងសង់ សាលាមត្តេយ្យសហគមន៍ និងសាលាមត្តេយ្យរដ្ឋ។ | - 21031 "សំណង់អគារ"<br>- 60053 "សម្ភារៈប្រើប្រាស់" | ☐<br>☐ |
| - ចំណាយលើការរៀបចំ ថែទាំ និងជួសជុលសួនកុមារនៅតាមសាលាមត្តេយ្យសហគមន៍/សាលាមត្តេយ្យរដ្ឋ។<br>- ជួសជុលរបងមត្តេយ្យសិក្សាសហគមន៍។ | - 60052 "សង្ហារិម"<br>- 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ" | ☐<br>☐<br>☐ |
| - ឧបត្ថម្ភ សម្រាប់គ្រូដែលជួលឱ្យបង្រៀននៅតាមសាលាមត្តេយ្យសហគមន៍។ | - 61093 "បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ" | ☐ |

| | | |
|---|---|---|
| - ចំណាយសម្រាប់បំប៉ន និងបណ្តុះបណ្តាលបច្ចេកទេស រៀន និងបង្រៀន គ្រូមត្តេយ្យសហគមន៍ មិនជាប់ស្តង់ដាររបស់ក្រសួងអប់រំយុវជន និងកីឡា។<br>- ចំណាយសម្រាប់បណ្តុះបណ្តាល និងផ្សព្វផ្សាយ និងជួលសេវាកម្មផ្សេងៗ សម្រាប់បណ្តុះបណ្តាល ស្តីពីសកម្មភាពសេវាសង្គមនៅសហគមន៍ សាលាឃុំ មណ្ឌលសុខភាព មត្តេយ្យសិក្សា សហគមន៍ និងសាលារៀនដូចជា សកម្មភាពបង្កើនចំណូលគ្រួសារ ការអប់រំឪពុកម្តាយ កិច្ចការពារកុមារ ការអភិវឌ្ឍន៍កុមារតូច និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស" | ☐ |
| - ការផ្តល់ឧបករណ៍ និងសម្ភារៈនានាសម្រាប់ដំណើរការមត្តេយ្យសិក្សាសហគមន៍ (តុ កៅអី កន្ទេល ក្រដាសពណ៌ ប្រដាប់ក្មេងលេង សៀវភៅរឿង ផ្ទាំងរូបភាព ក្តារខៀន ហ្វីត ប៊ិច ខ្មៅដៃ ជីស ការបិត កន្ត្រៃ ឧបករណ៍រៀបចំ សួនកុមារ)។ | - 62031 "ឧបត្ថម្ភសហគមន៍ និងរក្សាសណ្តាប់ធ្នាប់ សន្តិសុខសង្គម" | ☐ |
| **១.៤.ការអប់រំបឋមសិក្សា និងមធ្យមសិក្សា** | | |
| - ចំណាយសាងសង់សាលារៀនថ្មីៗនៅតំបន់ដាច់ស្រយាល។ | - 21031 "សំណង់អគារ" | ☐ |
| - ចំណាយលើការរៀបចំ ថែទាំ និងជួសជុលសួនកុមារ និងកន្លែងលេងកីឡានៅសាលាបឋមសិក្សា និងមធ្យមសិក្សា។<br>- ជួសជុលរបងសាលារៀន ។ | - 60053 "សម្ភារៈប្រើប្រាស់"<br>- 60052 "សង្ហារិម"<br>- 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ"<br>- 61051 "ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែននេសាទ" | ☐<br>☐<br>☐<br>☐<br>☐ |
| - ផ្តល់អាហារពេលព្រឹក ដល់សិស្សមកពីគ្រួសារក្រីក្រ តាមសាលារៀន (មត្តេយ្យសហគមន៍ មត្តេយ្យរដ្ឋ និងបឋមសិក្សា)។ | - 62023 "អាហារ និងសម្ភារ (ស្បៀង)" | ☐ |
| **១.៥.កិច្ចការពារស្ត្រី និងកុមារ** | | |
| - ចំណាយធ្វើដំណើរសម្រាប់កុមារ ស្ត្រីរងគ្រោះ និងគ្រួសារដើម្បីទៅទទួលសេវា។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល" | ☐ |

| | | |
|---|---|---|
| - ចំណាយធ្វើដំណើរ ក្នុងពេលអន្តរាគមន៍ជួយកុមារ ស្ត្រីរងគ្រោះ និងគ្រួសារ។<br>- ចំណាយធ្វើដំណើរសម្រាប់គ្រូនិងសិក្ខាកាម ក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីសង្គមកិច្ច (ពាក់កណ្តាលអាជីព)។<br>- ចំណាយធ្វើដំណើរសម្រាប់ចុះបើកវគ្គដល់មាតាបិតា និងអ្នកថែទាំកុមារស្តីពីការចិញ្ចឹមថែទាំកូនតាមបែបវិជ្ជមាន។ | - 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" | ☐<br>☐<br>☐<br>☐ |
| - ចំណាយសម្រាប់វគ្គបណ្តុះបណ្តាល មន្ត្រីសង្គមកិច្ច (ពាក់កណ្តាល អាជីព)។<br>- ចំណាយបើកវគ្គជំនាញវិជ្ជាជីវៈ សម្រាប់គ្រួសាររងគ្រោះ និងងាយរងគ្រោះ ព្រមទាំងគ្រួសារក្រីក្រ។<br>- ចំណាយសម្រាប់បើកវគ្គដល់មាតាបិតា និងអ្នកថែទាំកុមារស្តីពីការចិញ្ចឹមថែទាំកូនតាមបែបវិជ្ជមាន។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" | ☐<br>☐ |
| - ចំណាយបោះពុម្ពសៀវភៅកត់ត្រាព័ត៌មានភូមិ។ | - 60023 "ការបោះពុម្ព" | ☐ |
| - ចំណាយសម្រាប់រៀបចំកិច្ចប្រជុំតម្រង់ទិសជាមួយមេភូមិ និងតម្រង់ទិសស្តីពីអគ្រានុក្កូលដ្ឋានគ្រប់ប្រភេទដល់ស្មៀនឃុំ និងជំនួយការឃុំ សង្កាត់។ | - 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" | ☐ |
| - ចំណាយលើមធ្យោបាយបំពេញការងាររបស់ភ្នាក់ងារសង្គមកិច្ចឃុំ សង្កាត់ និងក្រុង ស្រុក ក្នុងនោះមាន÷ ទោចក្រយានយន្ត ត្រីចក្រយានយន្ត ឬរ៉ឺម៉ក កុំព្យូទ័រ ព្រីនធ័រ ម៉ាស៊ីនថតចម្លង និងម៉ាស៊ីនស្កែនជាដើម។ | - 60054 "សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន"<br>- 60055 "សម្ភារៈ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា" | ☐<br>☐ |
| - ចំណាយធ្វើដំណើរសម្រាប់មន្ត្រីក្រុង ស្រុក ចុះធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារ។<br>- ចំណាយចុះពិនិត្យតាមដាន ករណីសេវាសង្គមនិងបរិស្ថាន។ | - 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" | ☐<br>☐<br>☐<br>☐<br>☐ |
| - ចំណាយរៀបចំកិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលរបស់ភ្នាក់ងារសង្គមកិច្ច ជំនួយការសង្គម។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" | ☐<br>☐ |
| **១.៦.កិច្ចគាំពារសង្គម** | | |

| | | |
|---|---|---|
| - ឧបត្ថម្ភសម្រាប់ជំនួយការសង្គម/ភ្នាក់ងារសង្គមកិច្ចរបស់ក្រុង ស្រុក និងឃុំ សង្កាត់។<br>- ចំណាយធ្វើដំណើរ សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រកុមារ និងស្ត្រីងាយរងគ្រោះ ( កុមារក្រីក្រ រាប់បញ្ចូលទាំងកុមារពិការ និងកុមារដែលត្រូវបានទុកចោល ដោយសារឪពុកម្តាយធ្វើចំណាកស្រុក ព្រមទាំងកុមារនិងស្ត្រីដែលរងគ្រោះដោយសារ អំពើហិង្សាក្នុងគ្រួសារ)។<br>- សោហ៊ុយដឹកជញ្ជូន ឬធ្វើដំណើររបស់ជនក្រីក្រ ជនងាយរងគ្រោះ ជនពិការ កុមារក្រីក្រ កុមាររងគ្រោះ កុមារងាយរងគ្រោះ និងកុមារពិការ។<br>- សោហ៊ុយដឹកជញ្ជូន ឬ ធ្វើដំណើររបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ។ | - 61091 “ ចំណាយលើការជួលទីប្រឹក្សា និងអ្នកជំនួយការជាជនជាតិខ្មែរ និងបុគ្គលិក ជាប់កិច្ចសន្យាដែលជ្រើសរើសដោយរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផ្ទាល់ ”<br>- 60015 “ប្រេងឥន្ធនៈ និងប្រេងរំអិល”<br>- 61021 “ការជួលមធ្យោបាយដឹកជញ្ជូន ”<br>- 61121 “សោហ៊ុយដឹកជញ្ជូន ”<br>- 61122 “សោហ៊ុយបេសកកម្ម ”<br>- 61123 “សោហ៊ុយស្នាក់នៅ ” | ☐<br>☐<br>☐<br>☐<br>☐<br>☐ |
| - ចំណាយជួយជនរងគ្រោះ ដោយសារគ្រោះមហន្តរាយ ឬឧបទ្ទវហេតុផ្សេងៗ។ | - 62024 “ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ” | ☐ |
| - ចំណាយលើការទិញសម្ភារៈផ្គត់ផ្គង់ទឹកស្អាត អនាម័យ ជួសជុល ជម្រក ប្រាក់ឧបត្ថម្ភ និងស្បៀងអាហារសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ (សម្ភារៈលាងសម្អាតដៃ សាប៊ូ ធុងទឹក ពាងទឹក ធុងចម្រោះ សម្ភារៈភ្ជាប់បណ្តាញទឹក និងសម្ភារៈសម្រាប់សាងសង់បង្គន់អនាម័យដូចជា ចានបង្គន់ លូកង់ សម្ភារៈអនាម័យ សម្រាប់កូនក្មេង និងសម្ភារៈពាក់ព័ន្ធផ្សេងៗទៀត។ | - 60011 “សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ” | ☐ |
| - ចំណាយលើការធ្វើដំណើរ សម្រាប់បញ្ជូនកុមារ និងគ្រួសារដែលងាយរងគ្រោះទៅរកសេវាជំនួយសង្គម។<br>- ចំណាយលើការធ្វើដំណើរសម្រាប់បុគ្គលិកសង្គមកិច្ចផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ និងងាយរងគ្រោះ។<br>- សោហ៊ុយធ្វើដំណើរ របស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិក គ.ក.ន.ក ជំនួយការរដ្ឋបាលឃុំ សង្កាត់ ជំនួយការការងារសេវាសង្គម ក្រុមទ្រទង់សុខភាពភូមិ និងអ្នកពាក់ព័ន្ធក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងងាយរងគ្រោះកុមារ និងស្ត្រីក្រីក្រងាយរងគ្រោះ ជនពិការ ការបង្រួបបង្រួមកុមារជាមួយគ្រួសារ និងការតាមដានកុមារ ការគ្រប់គ្រងករណីការនាំកុមារ និងស្ត្រីដែលប្រឈមនឹងអំពើហិង្សា និង | - 60015 “ប្រេងឥន្ធនៈ និងប្រេងរំអិល”<br>- 61021 “ការជួលមធ្យោបាយដឹកជញ្ជូន ”<br>- 61121 “សោហ៊ុយដឹកជញ្ជូន ”<br>- 61122 “សោហ៊ុយបេសកកម្ម ”<br>- 61123 “សោហ៊ុយស្នាក់នៅ ” | ☐<br>☐<br>☐<br>☐<br>☐ |

| | | |
|---|---|---|
| ទទួលរងអំពើហិង្សា ទៅរកសេវាពាក់ព័ន្ធ និងអនុវត្តសកម្មភាពនានាដែលមានចែងក្នុងសេចក្ដីណែនាំនេះ។ | | |
| - ចំណាយឧបត្ថម្ភដល់មណ្ឌលបន្សាបគ្រឿងញៀន។ | - 62036 "ឧបត្ថម្ភដល់មណ្ឌលស្តារលទ្ធភាព ពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាល អភិវឌ្ឍ" | ☐ |
| - សម្ភារៈការិយាល័យសម្រាប់បម្រើសេវាសង្គមនិងបរិស្ថាន។ | - 60021 "សម្ភារៈការិយាល័យ" | ☐ |
| - ជួសជុលរបងសាលាឃុំ សង្កាត់។ | - 60012 "សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទ និងសំណង់ផ្សេងៗ"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ" | ☐<br>☐ |
| - ផ្តល់ (ប្រាក់ឧបត្ថម្ភ) ជំនួយការការងារសេវាសង្គមរដ្ឋបាលឃុំ សង្កាត់ ភ្នាក់ងារទ្រទ្រង់សុខភាពភូមិ ម្តាយបង្គោល និងអ្នកពាក់ព័ន្ធផ្សេងទៀត សម្រាប់សកម្មភាព លើកកម្ពស់ចំណេះដឹងការផ្សព្វផ្សាយកិច្ចប្រជុំ និងសេវាចុះមូលដ្ឋាន និងយុទ្ធនាការនានាក្នុងសកម្មភាពសេវាសង្គមតាមសហគមន៍។ | - 61093 "បុគ្គលិកសម្ដូហភាពសាធារណៈផ្សេងៗ" | ☐ |
| - ចំណាយសម្រាប់សិក្ខាសាលានិងកិច្ចប្រជុំនានាស្តីពីសកម្មភាពសេវាសង្គមនៅសហគមន៍ សាលាឃុំ មណ្ឌលសុខភាព មត្តេយ្យ សិក្សាសហគមន៍ និងសាលារៀន។ | - 61103"ប្រជុំ សិក្ខាសាលា និងសន្និសីទ" | ☐ |
| **១.៧.គណនេយ្យភាពសង្គម** | | |
| - ផ្សព្វផ្សាយព័ត៌មាន សេវាកម្ម និងលើកកម្ពស់តម្លាភាពជូនប្រជាពលរដ្ឋ និងសាធារណៈ (តាមរយៈការប្រជុំ សិក្ខាសាលា បិទផ្សាយជាសាធារណៈ ស្តីពីកញ្ចប់ព័ត៌មានរបស់ប្រជាពលរដ្ឋ លទ្ធផលបំពេញការងារ ការរៀបចំ និងការប្រើប្រាស់ថវិកា និងចែកចាយផ្ទាំង I4Cs ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ដល់អង្គភាពផ្តល់សេវាដែលពាក់ព័ន្ធ...ល)។<br>- បង្ហាញ និងពិភាក្សាអំពីលទ្ធផល I4Cs ក្នុងកិច្ចប្រជុំថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់។ | - 61103"ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 60021 "សម្ភារៈការិយាល័យ" | ☐<br>☐ |
| - កសាងសមត្ថភាពដល់អ្នកសម្របសម្រួល និងផ្តល់សេវាគណនេយ្យភាពសង្គម។ (តាមរយៈការបើកវគ្គបណ្តុះបណ្តាល និងប្រជុំតម្រង់ទិសដល់អ្នកផ្តល់សេវាគណនេយ្យភាពសង្គម)។ | - 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស"<br>- 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល" | ☐<br>☐ |

| | | |
|---|---|---|
| - បង្កើនការយល់ដឹង និងអភិវឌ្ឍសមត្ថភាពរបស់អ្នកផ្ដល់សេវាក្នុងដំណើរការត្រួតពិនិត្យតាមដាន ដោយប្រជាពលរដ្ឋ និងបច្ចេកទេស។ | - 61021 "ការជួលមធ្យោបាយដឹកជញ្ជូន"<br>- 61121 "សោហ៊ុយដឹកជញ្ជូន"<br>- 61122 "សោហ៊ុយបេសកកម្ម"<br>- 61123 "សោហ៊ុយស្នាក់នៅ" | ☐<br>☐<br>☐<br>☐ |
| - ...<br>- ... | - ...<br>- .... | |
| **២.បរិស្ថាន** | | |
| **២.១.ការគ្រប់គ្រងសំណល់ រឹង រាវ** | | |
| - សេវាប្រមូលសំរាម សំណល់រឹង រាវ។<br>- ការកែច្នៃសំណល់រឹង និងផលិតផលប្លាស្ទិក។<br>- រៀបចំប្រព្រឹត្តកម្មសំណល់រាវ។<br>- ការសាងសង់ ឡដុតសំរាម។<br>- ចំណាយប្រតិបត្តិការ ឡដុតសំរាម។ | - 61011 "សេវាអនាម័យ"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ"<br>- 62031 "ឧបត្ថម្ភសហគមន៍ និងរក្សាសណ្ដាប់ធ្នាប់ សន្ដិសុខសង្គម"<br>- 61054 "ការថែទាំបណ្ដាញផ្សេងៗ" | ☐<br>☐<br>☐<br>☐ |
| - ទិញធុងសំរាមដាក់តាមទីសាធារណៈ។<br>- សកម្មភាពលើកកម្ពស់ទីសាធារណៈ (ទិញធុងសម្រាម អំបោស ទុយោទឹក ធុងទឹក..... )។<br>- សកម្មភាពដាំដើមឈើតាមទីសាធារណៈ។<br>- អប់រំផ្សព្វផ្សាយ និងជំរុញឲ្យមានការចូលរួមពីប្រជាពលរដ្ឋអំពីការកាត់បន្ថយសំណល់ ការគ្រប់គ្រងសំរាម ការវេចខ្ចប់សំរាម ការញែកសំរាម សំណល់រឹង រាវ ទីប្រជុំជន ។<br>- បណ្ដុះបណ្ដាលការគ្រប់គ្រងសំណល់រឹង រាវ ដល់អ្នកពាក់ព័ន្ធ។<br>- ធ្វើយុទ្ធនាការ និងជម្រុញការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ផលិតផលប្លាស្ទិក និងការបំភាយឧស្ម័នក្នុងបរិយាកាស ។ | - 60011 "សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ"<br>- 60015 "ប្រេងឥន្ធនៈ និងប្រេងរំអិល"<br>- 60033 "ពូជ និងកូនរុក្ខជាតិ"<br>- 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ"<br>- 61041 "សោហ៊ុយបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេស" | ☐<br>☐<br>☐<br>☐<br>☐ |
| **២.២.ការគ្រប់គ្រងអនាម័យ** | | |
| - សាងសង់អណ្ដូងទឹក។<br>- សាងសង់បង្គន់អនាម័យ ។<br>- បំពាក់ប្រព័ន្ធចម្រោះទឹកស្អាត 60051។ | - 62031 "ឧបត្ថម្ភសហគមន៍ និងរក្សាសណ្ដាប់ធ្នាប់ សន្ដិសុខសង្គម"<br>- 61052 "ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ" | ☐<br>☐ |

| | | |
|---|---|---|
| - ផ្សព្វផ្សាយ បណ្តុះបណ្តាលអប់រំអំពីការប្រើប្រាស់បង្គន់អនាម័យ និងទឹកស្អាត ។ | - 61041 “សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ”<br>- 60051“សម្ភារៈនិងបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យា ” | ☐<br>☐ |
| **២.៣.ការគ្រប់គ្រងតំបន់ធម្មជាតិ** | | |
| - ការអប់រំផ្សព្វផ្សាយ ការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងតំបន់ និងសហគមន៍ការពារធម្មជាតិ និងអភិវឌ្ឍន៍ធនធានព្រៃឈើ ព្រៃលិចទឹក និងធនធានជលផល។<br>- គាំទ្រសកម្មភាពបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ នៅក្នុងតំបន់ និងសហគមន៍ការពារធម្មជាតិ និងអភិវឌ្ឍន៍ ធនធានព្រៃឈើ ព្រៃលិចទឹក និងធនធានជលផល។ | - 61103“ប្រជុំ សិក្ខាសាលា និងសន្និសីទ ”<br>- 61041 “សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ”<br>- 60015 “ប្រេងឥន្ធនៈ និងប្រេងរំអិល”<br>- 60054 “ សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន”<br>- 60018 “ សម្ភារៈផ្គត់ផ្គង់ផ្សេងៗ ”<br>- 60014 “សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ ”<br>- 60031 “ស្បៀង ” | ☐<br>☐<br>☐<br>☐<br>☐<br>☐<br>☐ |
| - .<br>- . | - .<br>- . | |